# មេរៀនទី ១០៥៖ អេសាយប្រាប់ពីការយាងមករបស់ព្រះយេស៊ូវ

អេសាយ ៩៖១-៦

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/ZbU-r6Agg1g

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/RLBibPAWGPU

**គោលបំណង៖** ព្រះយេស៊ូវគឺជាព្រះពេញដោយអំណាច។

**ខគម្ពីរចងចាំ៖ អេសាយ ៩៖៦ខ** *"ហើយគេនឹងហៅព្រះនាមទ្រង់ថា ព្រះដ៏ជួយគំនិតយ៉ាងអស្ចារ្យ ព្រះដ៏មានព្រះចេស្តា ព្រះវរបិតាដ៏គង់នៅអស់កល្ប និងជាម្ចាស់នៃមេត្រីភាព។ "*

**ចំរៀង** ( *យូធូបលីង* )៖

១. អំណរដ៏ពិត https://youtu.be/ea-vJudBOEU

២. ព្រះចាត់បុត្រា https://youtu.be/eDsWfEtrnS0

៣. ខ្ញុំលើកព្រះនាមទ្រង់ឡើង https://youtu.be/rPE5QOHbo70

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «តើនរណាខ្លាំងជាង ?»

សម្ភារៈដែលត្រូវការ៖ កៅអី៣ ស្ករគ្រាប់ ក្រមា៣



១. ចែកកុមារជា ៣ ក្រុម

២. ជ្រើសរើសតំណាងក្រុមម្នាក់មកលេង ដោយយកក្រមា មកចងចង្កេះកុមារទាំងបីនាក់នោះ

៣. ចងចុងក្រមាកុមារទាំង៣នោះ ភ្ជាប់គ្នារួចដាក់ពួកគេនៅចំកណ្តាល

៤. ដាក់កៅអី៣ ដោយមានស្ករគ្រាប់ពីលើ រួចដាក់នៅពីមុខកុមារទាំង៣នោះ នៅកន្លែង ៣ ផ្សេងៗគ្នា។

៥. នៅពេលដែលគ្រូស្រែកថា "ចាប់ផ្តើម" កុមារទាំង៣ត្រូវព្យាយាមទាញគ្នាទៅវិញទៅមកដើម្បីយកស្ករ គ្រាប់ឲ្យបាន។

៦. កុមារណាដែលអាចយកស្ករគ្រាប់បានមុនគេក្រុមនោះជាអ្នកឈ្នះ។

៧. លេងល្បែងនេះ រហូតដល់កុមារគ្រប់ៗគ្នាបានលេងអស់។ ក្រុមណាដែលសមាជិករបស់ខ្លួនទទួលបានជ័យជំនះច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។

៨. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា វាគឺមិនមានភាពងាយស្រួលនោះទេ ក្នុងការដណ្តើមយកស្ករគ្រាប់នោះ។ ប៉ុន្តែកុមារដែលមានកម្លាំងខ្លាំងជាងគេនឹងឈ្នះល្បែងនេះ។ សូមជឿជាក់ថា ព្រះរបស់យើងដែលយាងមកក្នុងថ្ងៃបុណ្យណូអែល គឺជាព្រះដ៏មានព្រះចេស្តា និងអស្ចារ្យជាងគេទាំងអស់។

## ៤. ការណែនាំមេរៀន

តើអ្នកធ្លាប់ទន្ទឹងរង់ចាំមើលផ្លូវនរណាម្នាក់ ដែលអ្នកស្រលាញ់មកលេងអ្នកដែរឬទេ? តើអ្នកនឹងមានអារម្មណ៍ដូចម្តេច នៅពេលដែលអ្នករង់ចាំបុគ្គលម្នាក់នោះ? តើអ្នកមានអារម្មណ៍សប្បាយរីករាយ? រំភើប?ឬក៏មានអារម្មណ៍ក្រៀមក្រំនៅពេលដែលបុគ្គលម្នាក់នោះមកយឺត? ព្រះបានសន្យាថាទ្រង់នឹងបញ្ជូនបុគ្គលដែលពិសេសម្នាក់សម្រាប់ប្រជាជនអ៊ីស្រាអ៊ែល។ ទ្រង់បានសន្យាថានឹងបញ្ជូនព្រះមេស្ស៊ីមក គឺព្រះអម្ចាស់យេស៊ូវគ្រីស្ទ តាមរយៈហោរាដែលមានឈ្មោះថា អេសាយជាច្រើនឆ្នាំមុនពេល ដែលព្រះយេស៊ូវយាងមក។ ថ្ងៃនេះយើងនឹងរៀនអំពីការពិពណ៌នា របស់ហោរាអេសាយអំពីព្រះមេស្ស៊ី គឺព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះបានមានបន្ទូលប្រាប់ហោរាអេសាយថា ព្រះយេស៊ូវនឹងយាងមក ពួកយើងបានដឹងថាព្រះតែងតែរក្សាការសន្យារបស់ទ្រង់ជានិច្ច។ នៅពេលដែលអេសាយនិយាយថា ព្រះយេស៊ូវនឹងយាងមកគ្មាននរណាម្នាក់ដឹងច្បាស់ថាទ្រង់ជានរណានោះទេ ហើយក៏គ្មាននរណាម្នាក់ដឹងថា ទ្រង់ត្រូវប្រើពេលវេលាយូរប៉ុនណាក្នុងការយាងមកផែនដីនោះដែរ។ ប៉ុន្តែ ហោរាអេសាយបានប្រើពាក្យដើម្បីពណ៌នាពីទ្រង់ថា ព្រះអស្ចារ្យ ព្រះដ៏មានព្រះចេស្តា ព្រះវរបិតា ដ៏គង់នៅអស់កល្ប និងជាម្ចាស់នៃមេត្រីភាព។

តើពាក្យថាអស្ចារ្យមានន័យដូចម្តេច? អស្ចារ្យមានន័យថា ព្រះយេស៊ូវពិតជាល្អខ្លាំងណាស់។ ព្រះគម្ពីរក៏បានប្រាប់យើងថា ទ្រង់មានព្រះចេស្តា។ មានព្រះចេស្តាមានន័យថា ទ្រង់មានអំណាចខ្លាំងក្លាណាស់។ ហើយព្រះគម្ពីរក៏បានប្រាប់យើងថា ព្រះវរបិតាដ៏គង់នៅអស់កល្ប មានន័យថា ទ្រង់គ្មានការចាប់ផ្តើម ហើយក៏គ្មានការបញ្ចប់ដែរ។ ព្រះយេស៊ូវនឹងរស់នៅជារៀងរហូត! ព្រះគម្ពីរបាននិយាយថា ជាម្ចាស់នៃមេត្រីភាព គឺមានន័យថា ព្រះយេស៊ូវនឹងធ្វើជាអ្នកដឹកនាំដែលនាំសេចក្តីសុខសាន្តដល់រាស្ត្ររបស់ទ្រង់។

ស្តាប់ទៅព្រះយេស៊ូវពិតជាអស្ចារ្យមែនអត់? មនុស្សម្នាពិតជាមានការរំភើបជាខ្លាំងនៅពេលដែលឮថាព្រះយេស៊ូវនឹងយាងមកនោះ។ ពេលមួយរាស្ត្ររបស់ព្រះបានដឹងថា ព្រះយេស៊ូវកំពុងតែយាងមកពួកគេបានធ្វើការរង់ចាំ និងទន្ទឹងមើលផ្លូវរបស់ព្រះអង្គគ្រប់ពេល។ រាស្ត្ររបស់ព្រះបានធ្វើការរង់ចាំអស់រយៈពេលយ៉ាងយូរមុនពេលដែលព្រះយេស៊ូវយាងមក។

ព្រះបានរក្សាការសន្យារបស់ព្រះអង្គ ដោយបានបញ្ជូនព្រះយេស៊ូវឲ្យមកកាលពី ២០០០ឆ្នាំមុន! ព្រះយេស៊ូវ គឺជាព្រះអស្ចារ្យ ព្រះមានព្រះចេស្តា ព្រះវរបិតាដ៏គង់នៅអស់កល្ប និងជាម្ចាស់នៃមេត្រីភាព ទ្រង់គង់នៅជាមួយយើង! តើអ្នករំភើបក្នុងការអបអរសាទរព្រះយេស៊ូវដែលបានយាងមកសង្គ្រោះយើងដែរឬទេ? ទោះបីជាទ្រង់បានយាងមករកយើង តាំងពីតូចក៏ដោយក៏ទ្រង់បានធ្វើរឿងដ៏អស្ចារ្យ និងបង្ហាញពីព្រះចេស្តារបស់ទ្រង់ជាច្រើនដើម្បីជួយសង្គ្រោះយើង! សូមចែករំលែកដំណឹងល្អនេះដល់មិត្តភ័ក្តិរបស់យើង ដើម្បីឲ្យពួកគេក៏អាចថ្វាយបង្គំ ហើយទទួលបានការសង្គ្រោះតាមរយៈព្រះយេស៊ូវដែរ!

## ៦. សំនួរពិភាក្សា

១. តើហោរាមួយណាដែលបានទស្សន៍ទាយអំពីការយាងមករបស់ព្រះយេស៊ូវ? *(ហោរាអេសាយ)*

២. តើហោរាបានពិពណ៌នាអំពីព្រះយេស៊ូវដោយរបៀបណា?
*(ព្រះដ៏អស្ចារ្យ ព្រះដ៏មានព្រះចេស្តា ព្រះវរបិតាដ៏គង់នៅអស់កល្ប និងជាម្ចាស់នៃមេត្រីភាព)*

៣. សូមចែករំលែកពីការអស្ចារ្យដែលព្រះបានធ្វើនៅក្នុងជីវិតរបស់អ្នក។ *(ទុកឲ្យកុមារជាអ្នកឆ្លើយ)*

៤. តើអ្នកនឹងប្រាប់មិត្តភក្តិរបស់អ្នកដោយរបៀបណាពីការយាងមករបស់ព្រះយេស៊ូវ?
*(ទុកឲ្យកុមារជាអ្នកឆ្លើយ)*

**៧. ល្បែងកំសាន្ត «ផ្លុំពពុះសាប៊ូ»**



សម្ភារៈដែលត្រូវការ៖ ទុយោបឺត កែវជ័រ៣ សាប៊ូលាងចាន

១. ចែកកុមារជា៣ក្រុម ហើយឲ្យពួកគេឈរជាជួរ

២. ដាក់តុមួយសម្រាប់ក្រុមនីមួយៗ ហើយដាក់កែវជ័រដែលមានទឹកសាប៊ូនៅក្នុងនោះ។



៣. ឲ្យទុយយោទៅកុមារម្នាក់មួយ ពួកគេត្រូវផ្លុំទឹកសាប៊ូនោះម្នាក់ម្តង។ បន្តលេងល្បែងនេះ រហូតដល់ទឹកសាប៊ូនៅក្នុងកែវត្រូវបានផ្លុំជាពពុះអស់។

៤. ក្រុមណាដែលអាចផ្លុំទឹកសាប៊ូអស់ពីកែវមុន ក្រុមនោះនឹងឈ្នះល្បែងនេះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ពួកគេចាប់ផ្តើមដោយផ្លុំទឹក ប៉ុន្តែនៅពេលបញ្ចប់ពួកគេទទួលបានពពុះសាប៊ូជាច្រើន។ ព្រះយេស៊ូវគឺ ព្រះដ៏អស្ចារ្យ ព្រះដ៏មានព្រះចេស្តា ដែលតែងតែផ្តល់ឲ្យយើងនូវអ្វីដែលច្រើនជាងការទូលសុំរបស់យើងទៀតផង។

**៨. ខគម្ពីរចងចាំ**

**អេសាយ ៩៖៦** " ហើយគេនឹងហៅព្រះនាមទ្រង់ថា ព្រះដ៏ជួយគំនិតយ៉ាងអស្ចារ្យ ព្រះដ៏មានព្រះចេស្តា ព្រះវរបិតាដ៏គង់នៅអស់កល្ប និងជាម្ចាស់នៃមេត្រីភាព។ "

**៩. ហត្ថកម្ម «ព្រះយេស៊ូវគឺ......»**

សម្ភារៈដែលត្រូវការ៖ សូមព្រីនក្រដាសហត្ថកម្ម ដងឈើការ៉េម កូល័រ កន្ត្រៃ និងការបិត




១. ឱ្យកុមារគ្រប់គ្នាតុបតែងផ្កាយទាំងបួនដែលមានការពិពណ៌នាអំពី ព្រះយេស៊ូវ ហើយកាត់ផ្កាយចេញមក។



២. ឲ្យកុមារបិតផ្កាយពីរនៅចុងម្ខាងនៃដងឈើការ៉េមសងខាង និងផ្កាយពីរទៀតនៅចុងម្ខាងទៀតនៃដង ឈើការ៉េម។

៣. កុមារអាចប្រើបន្ទះឈើការ៉េមជាមួយនឹងការពិពណ៌នាអំពីព្រះយេស៊ូវ ដើម្បីទន្ទេញខគម្ពីចងចាំ របស់ពួកគេ។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
យើងបានរៀនអំពីទិដ្ឋភាពខុសៗគ្នាជាច្រើនអំពីជីវិតរបស់ព្រះយេស៊ូវ និងការបម្រើរបស់ទ្រង់នៅលើផែនដីនេះ។ ប៉ុន្តែសូមឲ្យយើងកុំបំភ្លេចអំពីការដែលព្រះអង្គបានធ្វើសម្រាប់យើង។ ទ្រង់តែមួយអង្គគត់ដែលសាកសមនឹងទទួលបានការសរសើរពីយើង។ នៅពេលដែលអ្នកគិតអំពីព្រះយេស៊ូវ តើរឿងទីមួយដែលអ្នកគិតដល់នោះជាអ្វី? តើព្រះយេស៊ូវជាអ្វីចំពោះអ្នក? ជាគ្រូបង្រៀន ជាអ្នកបម្រើ ជាគ្រូអធិប្បាយ ជាបុគ្គលដែលឆ្លាត ឬក៏ជាព្រះអង្គសង្គ្រោះ? ផ្តោតលើឃ្លាចុងក្រោយ-ព្រះអង្គសង្គ្រោះ។ ប្រសិនបើអ្នក ចំណាយពេលពីរនាទីជារៀងរាល់ព្រឹក ដើម្បីសញ្ជឹងគិតពីរបៀបដែលព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់អ្នកនោះ តើវាអាចផ្លាស់ប្តូរជីវិតប្រចាំថ្ងៃរបស់អ្នកដោយរបៀបណា? សូមសាកល្បងមើល!

# ព្រះយេស៊ូវគឺ...

ព្រះដ៏មានព្រះចេស្តា

ព្រះដ៏ជួយគំនិត
យ៉ាងអស្ចារ្យ

ជាម្ចាស់នៃ
មេត្រីភាព

ព្រះវបិតាដ៏គង់
នៅអស់កល្ប

ព្រះយេស៊ូវគឺ...

ព្រះដ៏មានព្រះចេស្តា

ព្រះដ៏ជួយគំនិត
យ៉ាងអស្ចារ្យ

ជាម្ចាស់នៃ
មេត្រីភាព

ព្រះវបិតាដ៏គង់
នៅអស់កល្ប